## ឱកាសពិសេសសំរាប់
## ការពង្រឹងសមត្ថភាពសង្គមស៊ីវិល
## កម្មវិធីបណ្ដុះបណ្ដាលដំបូងបំផុតនៅក្នុងប្រទេសកម្ពុជា ស្ដីពី ការទទួលខុសត្រូវសង្គម

ធនាគារពិភពលោកប្រចាំប្រទេសកម្ពុជា តាមរយៈកម្មវិធីពង្រឹងសមត្ថភាពដើម្បីការទទួលខុសត្រូវសង្គម (PECSA) នឹងបើកវគ្គបណ្ដុះបណ្ដាល ដំបូងបំផុត នៅក្នុងប្រទេសកម្ពុជា ស្ដីពី **ការទទួលខុសត្រូវសង្គម** ចាប់ពី**ថ្ងៃទី ២៤ មិនា រហូតដល់ថ្ងៃទី ១២ មេសា ២០០៨។**

វិទ្យាស្ថានអន្តរជាតិដែលឈានមុខគេចំនួនពីរនៅក្នុងតំបន់អាស៊ី នឹងនាំយកនូវបទពិសោធន៍ជាក់ស្ដែងរបស់ពួកគេស្ដីពី ការទទួលខុសត្រូវសង្គម និង អភិបាលកិច្ចល្អ មកចែករំលែកជាមួយអ្នកអនុវត្តការងារនៅកម្ពុជា តាមរយៈវគ្គបណ្ដុះបណ្ដាលមួយដែលមានរយៈពេល ៣ សប្ដាហ៍។ កម្មវិធីសិក្សាសំរាប់វគ្គបណ្ដុះបណ្ដាលដំបូងបំផុតស្ដីពី **ការទទួលខុសត្រូវសង្គម** ក្នុងសប្ដាហ៍ទី១ នឹងគ្របដណ្ដប់នូវរាល់បញ្ហាទូទៅនៃការចូលរួមចំនែករបស់អង្គការសង្គមស៊ីវិល ទៅក្នុងកិច្ចការទទួលខុសត្រូវសង្គម និង អភិបាលកិច្ចល្អ ដោយឡែកសប្ដាហ៍ទី២ និង ទី៣ កម្មវិធីសិក្សានេះនឹងផ្ដោតសំខាន់ទៅលើបញ្ហាទាំងឡាយណាដែលពាក់ព័ន្ធទៅនឹង ការគ្រប់គ្រងដីធ្លី និង ធនធានធម្មជាតិ។

នេះគឺជាវគ្គបណ្ដុះបណ្ដាលដំបូងបំផុត ក្នុងចំនោមវគ្គបណ្ដុះបណ្ដាលស្ដីពី **ការទទួលខុសត្រូវសង្គម** បន្តបន្ទាប់ទៀត ដែលនឹងត្រូវរៀបចំឡើងដោយកម្មវិធី PECSA ក្នុងរយៈពេលពីរឆ្នាំខាងមុខ។ កម្មវិធីបណ្ដុះបណ្ដាលនេះ និងឈានទៅរកការផ្ដល់សញ្ញាប័ត្រ (Diploma) ទៅដល់សិក្ខាកាម និងអាចមាលទ្ធភាពនាំទៅរកការប្រគល់ជូន សញ្ញាប័ត្រថ្នាក់អនុបណ្ឌិតផ្នែក **ការទទួលខុសត្រូវសង្គម និង អភិបាលកិច្ច** ទៅដល់សិក្ខាកាម ដែលមានបំណងសិក្សាបន្តដើម្បីទទួលបានសញ្ញាប័ត្រនេះ។ សិក្ខាកាមអាចជ្រើសរើសការចូលរួមក្នុងកម្មវិធីបណ្ដុះបណ្ដាលដែលមានរយៈពេល១សប្ដាហ៍ ២សប្ដាហ៍ រឺ ៣សប្ដាហ៍ អាស្រ័យទៅតាមចំណាប់អារម្មណ៍ និង ពេលវេលាដែលខ្លួនអាចលៃលកទៅបាន។

### តើនរណាខ្លះដែលអាចចូលរួមសិក្សាក្នុងកម្មវិធីបណ្ដុះបណ្ដាលនេះបាន?

បេក្ខជនដែលអញ្ជើញមកពីបណ្ដាអង្គការសង្គមស៊ីវិល (CSOs) ដែលរួមមានៈ (អង្គការមិនមែនរដ្ឋាភិបាល NGOs, អង្គការដែលមានមូលដ្ឋាននៅតាមសហគមន៍ CBOs, សមាគមន៍ប្រជាពលរដ្ឋ, សហជីព, អ្នកសារពតិមាន) និងស្ថាប័នរដ្ឋាភិបាលពាក់ព័ន្ធ នៅកំរិតថ្នាក់មូលដ្ឋាន ថ្នាក់ខេត្ត និង ថ្នាក់ជាតិ អាចមានសិទ្ធិដាក់ពាក្យសុំចូលសិក្សាក្នុងកម្មវិធីបណ្ដុះបណ្ដាលនេះបាន។

ដំណឹងស្ដីពីដំណើរការនៃការដាក់ពាក្យ និង ការជ្រើសរើស នឹងប្រកាសជុននៅពាក់កណ្ដាលខែកុម្ភៈ ឆ្នាំ២០០៨។ ប្រសិនបើលោក-អ្នកចាប់អារម្មណ៍ ហើយមានបណងដាក់ពាក្យសិក្សាក្នុងកម្មវិធីបណ្ដុះបណ្ដាលនេះ **សូមចងចាំ និង កត់ត្រាកាលបរិច្ឆេទខាងលើទៅក្នុងប្រតិទិនរបស់លោក-អ្នក។**

សំរាប់ព័តិមានបន្ថែមស្ដីពីកម្មវិធីរបស់យើងខ្ញុំ សូមទស្សនាវិបសៃថ៍: www.worldbank.org.kh (សំរាប់ភាសាខ្មែរ) រឺ www.worldbank.org/kh (សំរាប់ភាសាអង់គ្លេស) និង/រឺ ទំនាក់ទំនង **លោក ព្រាប កុល** តាមរយៈអស័យដ្ឋានអ៊ីម៉េលៈ kpreap@worldbank.org

PECSA គឺជាកម្មវិធីដែលផ្ដល់មូលនិធិដោយធនាគារពិភពលោកប្រចាំប្រទេសកម្ពុជា ហើយកម្មវិធីនេះត្រូវបានអនុម័តដោយក្រសួងមហាផ្ទៃ។ គោលបំនងរបស់ PECSA គឺ ខិតខំពង្រឹងសមត្ថភាពរបស់អង្គការសង្គមស៊ីវិល CSOs តាមរយៈផ្ដល់ការបណ្ដុះបណ្ដាលដល់ពួកគេឱ្យចេះប្រើប្រាស់វិធីសាស្ត្រ និង ឧបករណ៍ស្ដីពីការទទួលខុសត្រូវសង្គម កែសំរួលការអនុវត្តន៍លើការទទួលខុសត្រូវដែលមានលក្ខណៈជាសកលឱ្យស្របទៅតាមបរិបទប្រទេសកម្ពុជា ផ្ដល់ថវិកាដើម្បីអភិវឌ្ឍន៍ និង សាកល្បងអនុវត្តការងារទទួលខុសត្រូវសង្គម ព្រមទាំងគាំទ្រ និងលើកទឹកចិត្តឱ្យមានការចែករំលែកព័តិមាន និង ការកសាងបណ្ដាញក្នុងចំណោម អ្នកអនុវត្តការងារទទួលខុសត្រូវសង្គម។